**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៨-០២៨ ប្រ.ក

**ប្រកាស**
**ស្តីពី**
**ការកំណត់ទុនអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពី ការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ
- យោងប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ
- យោងប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់ទ្រនាប់ដើមទុន ដែលរួមមានដើមទុនខនស៊ើវេសិន (Capital Conservation) និងដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital) ដើម្បីពង្រឹងភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅ៖

- ពង្រឹងមូលដ្ឋានដើមទុនសម្រាប់បំពេញការខាតបង់នានាដែលអាចកើតឡើងពីហានិភ័យរបស់គ្រឹះស្ថាន
- បង្ការការធ្លាក់ចុះដើមទុនមិនឲ្យទាបជាងកម្រិតដើមទុនអប្បបរមា និង
- កាត់បន្ថយហានិភ័យ ដែលបណ្តាលមកពីទំនាក់ទំនងរវាងវិស័យហិរញ្ញវត្ថុ និងវដ្តសេដ្ឋកិច្ច (Pro-cyclicality)។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ដែលតទៅនេះហៅថា "គ្រឹះស្ថាន" ទាំងកម្រិតគ្រឹះស្ថាន និងកម្រិតគូបសរុប ប្រសិនបើមាន។ គ្រឹះស្ថានដែលមានកម្រិតគូបសរុបត្រូវអនុវត្តដូចគ្នានឹងការគណនាគូបសរុបក្នុងរបាយការណ៍ស្តីពី អនុបាតសាធនភាព។

**ប្រការ ៤.-**

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ដើមទុនថ្នាក់ទី ១** សំដៅដល់ដើមទុនថ្នាក់ទី១ ដូចមានចែងក្នុងប្រការ ៥ នៃប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

**ដើមទុនថ្នាក់ទី ២** សំដៅដល់ដើមទុនថ្នាក់ទី២ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

**ដើមទុនសរុប** សំដៅដល់ "មូលនិធិផ្ទាល់សុទ្ធ" ដូចមានចែងក្នុងប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ ដើមទុនសរុបរបស់គ្រឹះស្ថានគឺជាផលបូករវាងដើមទុនថ្នាក់ទី១ និងដើមទុនថ្នាក់ទី២។

**ទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ** សំដៅដល់ផលបូកនៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

**អនុបាតសាធនភាព** សំដៅដល់ការគណនាដូចមានចែងក្នុងប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

**អនុបាតដើមទុនថ្នាក់ទី១** សំដៅដល់ផលធៀបរវាងដើមទុនថ្នាក់ទី១ និងទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

**អនុបាតដើមទុនសរុប** សំដៅដល់ផលធៀបរវាងដើមទុនសរុប និងទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

**កម្រិតដើមទុនអប្បបរមា (MCR)** សំដៅដល់ការតម្រូវឲ្យគ្រឹះស្ថានត្រូវរក្សាកម្រិតដើមទុនអប្បបរមាជាអចិន្ត្រៃយ៍ដូចខាងក្រោម ប្រសិនបើមិនមានការកំណត់ជាក់លាក់ដូចមានចែងក្នុងប្រការ ២០ នៃប្រកាសនេះ៖

- អនុបាតដើមទុនថ្នាក់ទី១ អប្បបរមា (MCR1) ស្មើ ៧,៥% មានន័យថា ដើមទុនថ្នាក់ទី១ ត្រូវស្មើ ឬច្រើនជាង ៧,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ
- ដើមទុនថ្នាក់ទី១ ត្រូវស្មើ ឬច្រើនជាង ៥០% នៃដើមទុនសរុប និង
- អនុបាតដើមទុនសរុបអប្បបរមា (MCRt) ស្មើ ១៥% មានន័យថាដើមទុនសរុប ត្រូវស្មើ ឬច្រើនជាង ១៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

**ប្រាក់ចំណេញ** សំដៅដល់ប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុដែលអាចបែងចែកបានដោយត្រូវបានគណនាមុនពេលដកចេញនូវធាតុដែលមិនអាចបែងចែកផ្សេងៗ ដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។ ប្រាក់ចំណេញត្រូវបានគណនាក្រោយការបង់ពន្ធ ដែលត្រូវបានរាយការណ៍មុនពេលដកចេញនូវធាតុដែលអាចបែងចែកបាន។ ដូច្នេះ ផលប៉ះពាល់លើកាតព្វកិច្ចបង់ពន្ធ ត្រូវគណនាសារឡើងវិញ នៅពេលដែលមានការបែងចែកប្រាក់ចំណេញ។

## ជំពូកទី ២
## ទ្រនាប់ដើមទុនខនស៊ើវេសិន (Capital Conservation Buffer)

### ប្រការ ៥.-

ក្នុងស្ថានភាពហិរញ្ញវត្ថុធម្មតា គ្រឹះស្ថានត្រូវមានទ្រនាប់ដើមទុនខនស៊ើវេសិន ដើម្បីធានាថាគ្រឹះស្ថានអាចទប់ទល់នឹងការធ្លាក់ចុះនៃដើមទុននៅពេលមានការខាតបង់។ នៅពេលទ្រនាប់ដើមទុនខនស៊ើវេសិនធ្លាក់ចុះមួយចំណែក ឬទាំងស្រុង គ្រឹះស្ថានត្រូវបំពេញឡើងវិញឲ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន។ ក្នុងករណីមិនអាចបំពេញបានភ្លាម គ្រឹះស្ថានត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវ "ផែនការគ្រប់គ្រងដើមទុន" ដោយត្រូវពន្យល់អំពីវិធីសាស្ត្រ និងកំណត់កាលបរិច្ឆេទដែលគ្រឹះស្ថានត្រូវបំពេញឡើងវិញនូវទ្រនាប់ដើមទុនខនស៊ើវេសិនដែលខ្វះនោះ។

### ប្រការ ៦.-

ទ្រនាប់ដើមទុនខនស៊ើវេសិន ត្រូវបង្កើនទៅក្នុងដើមទុនថ្នាក់ទី១ ដែលមានគុណភាពខ្ពស់ ពោលគឺ ដើមទុនចុះបញ្ជី និង/ឬ ទុនបម្រុងដែលមិនអាចបែងចែកបាន។

**ប្រការ ៧.-**

គ្រឹះស្ថាន ត្រូវរក្សាកម្រិតទ្រនាប់ដើមទុនខនស៊ើវេសិនបន្ថែមលើកម្រិតដើមទុនថ្នាក់ទី១អប្បបរមា (MCR1)។ កម្រិតទ្រនាប់ដើមទុនខនស៊ើវេសិន ត្រូវស្មើ ២,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យលើកលែងតែមានការកំណត់ផ្សេងដោយធនាគារជាតិនៃកម្ពុជា។ ដូច្នេះ ផលបូកសរុបនៃអនុបាតដើមទុនថ្នាក់ទី១ (៧,៥%) និងកម្រិតទ្រនាប់ដើមទុនខនស៊ើវេសិន (២,៥%) មិនត្រូវតិចជាង ១០% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

**ប្រការ ៨.-**

ក្នុងករណីដែលគ្រឹះស្ថានមានកម្រិតអនុបាតដើមទុនថ្នាក់ទី១លើសកម្រិតកំណត់អប្បបរមា (MCR1 = ៧,៥%) គ្រឹះស្ថានអាចប្រើប្រាស់ចំនួនទឹកប្រាក់ដើមទុនថ្នាក់ទី១ដែលលើស សម្រាប់បំពេញអនុបាតដើមទុនសរុបអប្បបរមា (MCRt = ១៥%) ប៉ុន្តែមិនអាចយកមករាប់បញ្ចូលក្នុងការគណនាទ្រនាប់ដើមទុនខនស៊ើវេសិនរបស់គ្រឹះស្ថានបានទេ យោងតាមកម្រិតដើមទុនអប្បបរមា (MCR) ដែលមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។ ទម្រង់របាយការណ៍ និងការពន្យល់សម្រាប់ការគណនាកម្រិតទ្រនាប់ដើមទុនសម្រាប់គ្រឹះស្ថាន មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ២ រៀងគ្នា។

**ប្រការ ៩.-**

ការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុត្រូវបានហាមឃាត់ នៅពេលដែលអនុបាតដើមទុនថ្នាក់ទី១ (MCR1 = ៧,៥%) របស់គ្រឹះស្ថាន ស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុនខនស៊ើវេសិនដូចមានចែងនៅក្នុងប្រការ ១១ នៃប្រកាសនេះ។ ការហាមឃាត់នេះ អនុវត្តចំពោះការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុតែប៉ុណ្ណោះ ដោយមិនប៉ះពាល់ដល់ដំណើរការប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានឡើយ។

**ប្រការ ១០.-**

ការបែងចែកដែលអាចប៉ះពាល់ដល់ដើមទុនថ្នាក់ទី១ត្រូវបានហាមឃាត់មានដូចជា ការបែងចែកភាគលាភ ការទិញភាគហ៊ុនត្រលប់មកវិញ និងការទូទាត់លើប្រាក់រង្វាន់បុគ្គលិក ជាដើម។

**ប្រការ ១១.-**

គ្រឹះស្ថានមានកាតព្វកិច្ចរក្សាដើមទុនបម្រុងអប្បបរមាដូចបានកំណត់ក្នុងតារាង ១។

តារាង ១ បង្ហាញអំពីអនុបាតដើមទុនបម្រុងអប្បបរមាដែលគ្រឹះស្ថានត្រូវរក្សា ដើម្បីឲ្យស្របតាមអនុបាតដើមទុនថ្នាក់ទី១ តាមចតុភាគនីមួយៗ ដូចខាងក្រោម៖

- ចតុភាគទី១: ២៥% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ស្មើនឹង ០,៦២៥%
- ចតុភាគទី២: ៥០% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ស្មើនឹង ១,២៥%
- ចតុភាគទី៣: ៧៥% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ស្មើនឹង ១,៨៧៥%
- ចតុភាគទី៤: ១០០% នៃទ្រនាប់ដើមទុនខនស៊ើវេសិន ស្មើនឹង ២,៥%

*តារាង ១*

| អនុបាតដើមទុនថ្នាក់ទី១<br>Tier 1 Capital ratio | អនុបាតដើមទុនបម្រុងអប្បបរមា (គិតជាភាគរយនៃប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ)<br>Minimum Capital Conservation ratio (expressed as percentage of earnings) |
|---|---|
| **ចតុភាគទី១: ២៥% នៃទ្រនាប់ដើមទុនខនស៊ើវេសិន**<br>≥ MCR1 (៧,៥%) ដល់ (MCR1 + ០,៦២៥%) | ១០០ |
| **ចតុភាគទី២: ៥០% នៃទ្រនាប់ដើមទុនខនស៊ើវេសិន**<br>> (MCR1 + ០,៦២៥%) ដល់ (MCR1 + ១,២៥%) | ៨០ |
| **ចតុភាគទី៣: ៧៥% នៃទ្រនាប់ដើមទុនខនស៊ើវេសិន**<br>> (MCR1 + ១,២៥%) ដល់ (MCR1 + ១,៨៧៥%) | ៦០ |
| **ចតុភាគទី៤: ១០០% នៃទ្រនាប់ដើមទុនខនស៊ើវេសិន**<br>> (MCR1 + ១,៨៧៥%) ដល់ (MCR1 + ២,៥%) | ៤០ |
| **ក្នុងកម្រិតខ្ពស់ជាងទ្រនាប់ដើមទុនខនស៊ើវេសិន**<br>> (MCR1 + ២,៥%) | ០ |

អនុបាតដើមទុនបម្រុងអប្បបរមានៅក្នុងតារាង ១ បង្ហាញពីភាគរយនៃប្រាក់ចំណេញដែលគ្រឹះស្ថានមិនអាចបែងចែក នៅពេលដែលអនុបាតដើមទុនថ្នាក់ទី១ របស់គ្រឹះស្ថានស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុនខនស៊ើវេសិន។

គ្រឹះស្ថានដែលមានការខាតបង់ និងមានអនុបាតដើមទុនថ្នាក់ទី១ តិចជាង ១០% មិនអាចបែងចែកប្រាក់ចំណេញឡើយ។

សម្រាប់គោលបំណងនៃប្រកាសនេះ ការបែងចែកទាំងឡាយណា ដែលមិនធ្វើឲ្យដើមទុនថ្នាក់ទី១ អប្បបរមាថយចុះ មិនត្រូវបានហាមឃាត់ឡើយ។

ទម្រង់របាយការណ៍ក្នុងឧបសម្ព័ន្ធ ១ បង្ហាញពីការគណនាអនុបាតដើមទុនបម្រុងអប្បបរមាដោយផ្អែកលើស្ថានភាពរបស់គ្រឹះស្ថានពាក់ព័ន្ធនឹងការបន្ថែមទ្រនាប់ដើមទុន។ គ្រឹះស្ថានត្រូវរក្សាអនុបាតដើមទុនបម្រុងអប្បបរមានៅក្នុងរយៈពេលពេញមួយឆ្នាំ។ ទិន្នន័យអនុបាតដើមទុនបម្រុងអប្បបរមានៅចុងឆ្នាំហិរញ្ញវត្ថុជាមូលដ្ឋានសម្រាប់គណនាចំណែកនៃប្រាក់ចំណេញដែលត្រូវរក្សាទុកនៅក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់។

**ប្រការ ១២**.-

ធនាគារជាតិនៃកម្ពុជា អាចកំណត់កាលបរិច្ឆេទឲ្យបំពេញឡើងវិញនូវទ្រនាប់ដើមទុនតាមករណីនីមួយៗ ចំពោះគ្រឹះស្ថានណាដែលមានប្រតិបត្តិការស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុន។

**ប្រការ ១៣.-**

ក្នុងករណីដែលគ្រឹះស្ថានមានបំណងធ្វើការបែងចែកប្រាក់ចំណេញលើសពីការកំណត់ដូចមានចែងក្នុងប្រការ ១១ នៃប្រកាសនេះ គ្រឹះស្ថានត្រូវបង្កើនដើមទុនជាមុន ឬស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ដែលការអនុញ្ញាតនេះអាចធ្វើទៅបានលុះត្រាតែគ្រឹះស្ថានបានអនុវត្តវិធានការចាំបាច់នានាក្នុងការបង្កើនដើមទុនឲ្យស្មើ ឬលើសពីកម្រិតជាភាគរយនៃប្រាក់ចំណេញដែលបានហាមឃាត់ដូចមានចែងក្នុងតារាង ១។

## ជំពូកទី ៣
## ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital Buffer)

**ប្រការ ១៤.-**

ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលត្រូវបានរៀបចំឡើងដើម្បីធានាថា គ្រឹះស្ថានមានដើមទុនគ្រប់គ្រាន់សម្រាប់បំពេញការខាតបង់នានានៅពេលធនាគារជាតិនៃកម្ពុជាពិនិត្យឃើញថា ឥណទានមានកំណើនលើសលុបដែលអាចបណ្តាលឲ្យមានហានិភ័យជាប្រព័ន្ធ។ ធនាគារជាតិនៃកម្ពុជា អាចកំណត់ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ចាប់ពីកម្រិត ០% ទៅ ២,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ។

**ប្រការ ១៥.-**

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឲ្យគ្រឹះស្ថានរក្សាកម្រិតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលខុសៗគ្នា ដោយសារការវាយតម្លៃកំណើនឥណទានលើសលុបមានលក្ខណៈមិនដូចគ្នារវាងគ្រឹះស្ថាននីមួយៗ។

**ប្រការ ១៦.-**

ធនាគារជាតិនៃកម្ពុជា នឹងចេញសារាចរណែនាំដោយឡែក ដើម្បីកំណត់ ឬកែសម្រួលកម្រិតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល។

**ប្រការ ១៧.-**

ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលត្រូវបានកំណត់ដើម្បីដាក់បន្ថែមលើទ្រនាប់ដើមទុនខនស៊ើវេសិន។ សមាសធាតុនិងវិធីសាស្ត្រក្នុងការបំពេញ ឬបំពេញឡើងវិញនូវទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ត្រូវអនុវត្តដូចគ្នានឹងប្រការ ៥ និងប្រការ ៦ ខាងលើ។

ការហាមឃាត់ការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុត្រូវបានអនុវត្តដូចក្នុងប្រការ ៩ និងប្រការ ១០ ខាងលើនៅពេលដែលអនុបាតដើមទុនថ្នាក់ទី១ របស់គ្រឹះស្ថានស្ថិតក្នុងចតុភាគណាមួយនៃទ្រនាប់ដើមទុនសរុបដូចមានកំណត់ក្នុងតារាង ២ ខាងក្រោម។

តារាង ២ បង្ហាញអំពីអនុបាតដើមទុនបម្រុងអប្បបរមាដែលគ្រឹះស្ថានត្រូវរក្សា ដើម្បីឲ្យស្របតាមអនុបាតដើមទុនថ្នាក់ទី១ តាមចតុភាគនីមួយៗ។

អញ្ញត្តិ y គឺជាកម្រិតទ្រនាប់ដើមទុនបន្ថែមទៅលើអនុបាតដើមទុនថ្នាក់ទី១ ដែល y = (២,៥% + x)/៤ ក្នុងនោះ ២,៥% ជាទ្រនាប់ដើមទុនខនស៊ើវេសិន និងអញ្ញត្តិ X ជាទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលដែលនឹងត្រូវកំណត់ដោយធនាគារជាតិនៃកម្ពុជាស្របតាមប្រការ ១៦ ខាងលើ។

*តារាង ២*

| អនុបាតដើមទុនថ្នាក់ទី ១<br>**Tier 1 Capital ratio** | អនុបាតដើមទុនបម្រុងអប្បបរមា (គិតជាភាគរយនៃប្រាក់ចំណេញប្រចាំឆ្នាំហិរញ្ញវត្ថុ)<br>**Minimum Capital Conservation ratio (expressed as percentage of earnings)** |
|---|---|
| **ចតុភាគទី១: ២៥% នៃទ្រនាប់ដើមទុន**<br>≥ MCR1 (៧,៥%) ដល់ (MCR1 + y) | ១០០ |
| **ចតុភាគទី២: ៥០% នៃទ្រនាប់ដើមទុន**<br>> (MCR1 + y) ដល់ (MCR1 + 2y) | ៨០ |
| **ចតុភាគទី៣: ៧៥% នៃទ្រនាប់ដើមទុន**<br>> (MCR1 + 2y) ដល់ (MCR1 + 3y) | ៦០ |
| **ចតុភាគទី៤: ១០០% នៃទ្រនាប់ដើមទុន**<br>> (MCR1 + 3y) ដល់ (MCR1 + 4y) | ៤០ |
| **ក្នុងកម្រិតខ្ពស់ជាងទ្រនាប់ដើមទុន**<br>> (MCR1 + 4y) | ០ |

ការពន្យល់អំពីការគណនាកម្រិតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**ប្រការ ១៨.-**

ប្រកាសនេះ បំពេញបន្ថែមប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

**ប្រការ ១៩.-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ត្រូវអនុវត្តឲ្យបានពេញលេញតាម ប្រកាសលេខ ធ៧-០១០-១៨២ ប្រ.ក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ និងប្រកាសលេខ ធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ។

**ប្រការ ២០.-**

ដោយឡែក គ្រឹះស្ថានដែលធនាគារជាតិនៃកម្ពុជាតម្រូវឲ្យរក្សាអនុបាតសាធនភាពក្នុងកម្រិតមួយខ្ពស់ជាងកម្រិតកំណត់អប្បបរមា ត្រូវអនុវត្តបញ្ញត្តិដូចខាងក្រោម៖

- គ្រឹះស្ថានដែលមានកាតព្វកិច្ចបង្កើនអនុបាតសាធនភាព កម្រិតដើមទុនអប្បបរមាសម្រាប់បំពេញទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ជាកម្រិតដើមទុនអប្បបរមា ១៥% ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ បូកនឹងកាតព្វកិច្ចដើមទុនដែលបានតម្រូវឲ្យបង្កើនបន្ថែមដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ធ៧-០១១-០៨២ ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ស្ដីពី ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត។
- ធនាគារជាតិនៃកម្ពុជា អាចកំណត់ទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលផ្សេងៗគ្នាចំពោះគ្រឹះស្ថាន ដែលទ្រនាប់ដើមទុនទាំងពីរនេះសរុបមិនលើសពីកម្រិត ២,៥% លើកម្រិតដើមទុនអប្បបរមាដែលបានបន្ថែមរួចហើយ និងមិនតិចជាងកម្រិតដើមទុនអប្បបរមាដែលបានចែងក្នុងប្រការ ៧ និងប្រការ ១៤ នៃប្រកាសនេះ។
- គ្រឹះស្ថានដែលត្រូវរក្សាអនុបាតសាធនភាពក្នុងកម្រិតមួយខ្ពស់ជាងកម្រិតកំណត់អប្បបរមានឹងត្រូវអនុវត្តតាមការកំណត់ដោយឡែករបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ២១.-**

គ្រឹះស្ថានត្រូវរាយការណ៍ជាប្រចាំខែអំពីស្ថានភាពនៃទ្រនាប់ដើមទុនខនស៊ើវេសិន និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល ទៅតាមទម្រង់របាយការណ៍ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ១។

គ្រឹះស្ថាន ត្រូវបំពេញរបាយការណ៍ក្នុងឧបសម្ព័ន្ធ ១ រួមមាន ដើមទុនថ្នាក់ទី១ ដើមទុនថ្នាក់ទី២ និងទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ ដែលមានតួលេខដូចគ្នាទៅនឹងតួលេខក្នុងរបាយការណ៍ស្ដីពី អនុបាតសាធនភាព និងការគណនាមូលនិធិផ្ទាល់សុទ្ធ។

**ប្រការ ២២.-**

គ្រឹះស្ថាន ត្រូវអនុវត្តតាមបញ្ញត្តិពាក់ព័ន្ធនឹងទ្រនាប់ដើមទុនខនស៊ើវេសិនយ៉ាងតិចឲ្យបាន ៥០% នៃទ្រនាប់ដើមទុនដែលត្រូវបន្ថែម ឲ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ និងត្រូវបំពេញឲ្យបានពេញលេញមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធ ២។

ចំពោះការអនុវត្តតាមបញ្ញត្តិពាក់ព័ន្ធនឹងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល គ្រឹះស្ថានត្រូវអនុវត្តតាមការកំណត់ដែលមានចែងក្នុងសារាចរណែនាំដោយឡែក។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ២៣.-**

គ្រឹះស្ថានណាដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ២៤-**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២៥.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៨ កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៨
**ទេសាភិបាល**

**ជា ចាន់តូ**

**កន្លែងទទួល៖**
- ដូចប្រការ ២៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"